N°9
08-3-97

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៥ លេខ ៩ ថ្ងៃទី ០៨ ខែ មិនា ឆ្នាំ ១៩៩៧

# រាជកិច្ច

រួមមាន :

- ច្បាប់
- ព្រះរាជក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្តាហ៍

# មាតិកា

## I . ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ

០៣_៣_១៩៩៧ _ ព្រះរាជក្រឹត្យលេខ ជស/រកត/០២៩៧/០១ តែងតាំង ឯកឧត្តម ហេង ផល្លាកា ទីប្រឹក្សាផ្ទាល់របស់ឯកឧត្តម ឡូយ ស៊ីមឈាង អនុប្រធានទី ១ នៃរដ្ឋសភា ៦២៤

០៣_៣_១៩៩៧ _ ព្រះរាជក្រឹត្យលេខ ជស/រកត/០២៩៧/០២ តែងតាំង ឯកឧត្តម ខាច ឈាច៊ិន ទីប្រឹក្សាផ្ទាល់របស់ឯកឧត្តម ឡូយ ស៊ីមឈាង អនុប្រធានទី ១ នៃរដ្ឋសភា ៦២៥

## II - រាជរដ្ឋាភិបាល

### ១_អនុក្រឹត្យ

០៥_៣_១៩៩៧ _ អនុក្រឹត្យលេខ ១៦ អនក្រ.បក ស្ដីពីការបង្កើតអង្គភាពជាតិ សំរាប់តំបន់ពាណិជ្ជកម្មសេរី អាស៊ាន ៦២៦

០៥_៣_១៩៩៧ _ អនុក្រឹត្យលេខ ១៨ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ៦៣០

០៦_៣_១៩៩៧ _ អនុក្រឹត្យលេខ ១៩ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៦៣១

### ២_ សេចក្ដីសំរេច

០៣_៣_១៩៩៧_ សេចក្ដីសំរេចលេខ ១០ សសរ. ស្ដីពីការប្រគល់ភារកិច្ចតាមដាន និងសំរបសំរួលកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចតំបន់វិសាលភាពទន្លេមេគង្គ ៦៣២

០៣_៣_១៩៩៧_ សេចក្តីសំរេចលេខ ១១ សសរ. ស្តីពីការជ្រើសតាំងជា បេក្ខជនទទួលរង្វាន់ SASAKAWA 97 ៦៣៤

## III_ ការងារបណ្តាក្រសួង

### ១_ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

#### ប្រកាស

០៤_៣_១៩៩៧ _ ប្រកាសលេខ ០៥៣ សហវ.ប្រកគរ ស្តីពីការយកកំរៃលើមុខ ទំនិញ នៃអាគារ [illegible] ទំនិញរួចពន្ធ ៦៣៥

### ២_ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

#### ប្រកាស

០៤_៣_១៩៩៧ _ ប្រកាសលេខ ០៨១ ពណ.ផក.ប្រក ស្តីពីការបិទស្លាក ថ្លៃលើមុខទំនិញ និងផ្នែកសេវាកម្មគ្រប់ប្រភេទ ៦៣៦

### ៣_ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

#### ប្រកាស

០៣_៣_១៩៩៧_ ប្រកាសលេខ ២២៥ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី ម៉ាក់ ហោម ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការសិប្បកម្ម ផលិតគ្រឿង ៦៣៧

០៣_៣_១៩៩៧_ ប្រកាសលេខ ២២៦ ផក.ប្រក អនុញ្ញាតអោយលោក ចាំង ហុក ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងជាងក្រឡឹងដែក ៦៣៨
០៣_៣_១៩៩៧_ ប្រកាសលេខ ២២៧ ផក.ប្រក អនុញ្ញាតអោយលោក អ៊ាវ ហាប់ ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងជាងក្រឡឹងដែក ៦៣៨
០៣_៣_១៩៩៧_ ប្រកាសលេខ ២២៨ ផក.ប្រក អនុញ្ញាតអោយលោក តាត ឆាយ ជាម្ចាស់មូលដ្ឋានផលិតសំបកកង់សញ្ញា «ផែនដី» ផ្ទេរសិទ្ធិគ្រប់គ្រង ជូនលោក ហុង គៀង វិញ ៦៣៩
០៣_៣_១៩៩៧_ ប្រកាសលេខ ២២៩ ផក.ប្រក អនុញ្ញាតជូនលោក សៀក គួង ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការសិប្បកម្មផលិតឥដ្ឋការ៉ូ ៦៣៩
០៣_៣_១៩៩៧_ ប្រកាសលេខ ២៣០ ផក.ប្រក អនុញ្ញាតអោយលោក សាន់ សៀងហួត ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការសិប្បកម្មផលិតនំប៉័ង ៦៤០
០៣_៣_១៩៩៧_ ប្រកាសលេខ ២៣១ ផក.ប្រក អនុញ្ញាតអោយលោក យូ ហៀង ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការសិប្បកម្មផលិតនំផ្អែម ៦៤០
០៣_៣_១៩៩៧_ ប្រកាសលេខ ២៣២ ផក.ប្រក អនុញ្ញាតអោយលោក ហ៊ូ សំអុល ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការសិប្បកម្មកិនម្សៅអង្ករ ៦៤១
០៣_៣_១៩៩៧_ ប្រកាសលេខ ២៣៣ ផក.ប្រក អនុញ្ញាតអោយលោក ហុង ម៉ៅ ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការឧស្សាហកម្មតូចផលិតកៅស៊ូកង ៦៤១
០៣_៣_១៩៩៧_ ប្រកាសលេខ ២៣៤ ផក.ប្រក អនុញ្ញាតអោយលោក គី ឈាងហួត ជនជាតិខ្មែរ សញ្ជាតិកម្ពុជា ជាម្ចាស់សិប្បកម្មផលិតឥដ្ឋក្បឿង ផ្ទេរភារកិច្ចគ្រប់គ្រងជូនលោក ខឹម សម្បត្តិ វិញ ៦៤២

## ៤_ទីស្តីការរដ្ឋមន្ត្រីក្រសួងពត៌មាន

### ប្រកាស

០៣_៣_១៩៩៧_ ប្រកាសលេខ ០៨១ ពម.ប្រក អនុញ្ញាតអោយកាសែត «ជាតិ» បន្តការចេញផ្សាយឡើងវិញ ៦៤២

០៣_៣_១៩៩៧_ ប្រកាសលេខ ០៨២/៩៧ ពម.ប្រក ដាក់ពិន័យទស្សនាវដ្ដីឈ្មោះ FOCUS CAMBODIA ៦៤៣

០៤_៣_១៩៩៧_ ប្រកាសលេខ ០៨៣/៩៧ ពម.ប្រក អនុញ្ញាតអោយអ្នកស្រី ខៀវ មាលី បើកអាជីវកម្ម រោងពុម្ពឈ្មោះ BLOSSOM COTUS PUBLISBING COMPANY ៦៤៤

០៥_៣_១៩៩៧_ ប្រកាសលេខ ០៨៤/៩៧ ពម.ប្រក អនុញ្ញាតអោយអ្នកស្រី រស់ អួន [illegible]ម្ម រោងពុម្ពឈ្មោះ« អមរា» ៦៤៥

០៧_៣_១៩៩៧_ ប្រកាសលេខ ០៨៦/៩៧ ពម.ប្រក ទទួលស្គាល់លោក អ៊ុន សុខុម ចាងហ្វាងកាសែត «អ្នកប្រយុទ្ធ» ៦៤៦

០៧_៣_១៩៩៧_ ប្រកាសលេខ ០៨៧/៩៧ ពម.ប្រក អនុញ្ញាតអោយចេញផ្សាយបន្តឡើងវិញកាសែត «ភ្នំពេញថ្មី» ៦៤៨

## ៥_ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា

### ប្រកាស

០៥_៣_១៩៩៧_ ប្រកាសលេខ ១៨២ អយក.ប្រក ស្តីពីការអនុញ្ញាតអោយបោះពុម្ពសៀវភៅគណិតវិទ្យា សំរាប់សិស្សថ្នាក់ទី ៨ ៦៤៩

០៥_៣_១៩៩៧_ ប្រកាសលេខ ១៨៣ អយក.ប្រក ស្តីពីការអនុញ្ញាតអោយបោះពុម្ពសៀវភៅ គីមីវិទ្យា សំរាប់គ្រូថ្នាក់ទី ៨ ៦៥១

០៧_៣_១៩៩៧_ ប្រកាសលេខ ១៨៤ អយក.ប្រក ស្តីពីការប្តូរឈ្មោះសាលាបឋមសិក្សា «ទួលក្រសាំង» មកជាសាលាបឋមសិក្សា «អ៊ីរ៉ូហា ទួលក្រសាំង» ៦៥២

ខ

# ៦_ទីស្តីការក្រសួងធម្មការ និងសាសនា

## សេចក្តីសំរេច

០៣_៣_១៩៩៧_ សេចក្តីសំរេចលេខ ៤៣/៩៧ កធស អនុញ្ញាតជាគោលការណ៍ អោយបើកស្នាក់ការថ្វាយបង្គំព្រះ នៃសាសនាមីលិក ( ចិន ) មួយ កន្លែងនៅភូមិ កំពង់ត្រាចទី ១ ឃុំកំពង់ត្រាចខាងលើ ស្រុក កំពង់ត្រាច ខេត្តកំពត ៦៥៣

# I - ខុទ្ទកាល័យព្រះមហាក្សត្រ

## ព្រះរាជក្រឹត្យ

**ព្រះរាជក្រឹត្យ នស.រកត.០២៩៧.០១**

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- យោងតាមសេចក្តីសំរេចរបស់រដ្ឋសភា ស្តីពីការជ្រើសតាំងសម្តេច **ជា ស៊ីម** ជាប្រធានរដ្ឋសភា ឯកឧត្តម **ឡូយ ស៊ីមឈាង** ជាអនុប្រធានទី ១ នៃរដ្ឋសភា នាសម័យប្រជុំពេញ អង្គលើកទី ១ នីតិកាលទី ១ ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ១៩៩៣
- យោងតាមសំណើរបស់ប្រធានរដ្ឋសភាស្តីទី ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

### ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឯកឧត្តម **ហេង ផល្លាភា** ជាទីប្រឹក្សាផ្ទាល់របស់ឯកឧត្តម**ឡូយ ស៊ីមឈាង** អនុប្រធានទី ១ នៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើអនុរដ្ឋលេខាធិការ ។

**មាត្រា ២ :** នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងអគ្គលេខាធិការរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះអោយបានសំរេច ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៧

ប្រមុខរដ្ឋស្ដីទី

ហត្ថលេខា

**ជា ស៊ីម**

* * *

**ព្រះរាជក្រឹត្យ ជស.អកត.០២៩៧.០១**

**យើង**

**ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ វរ្ម័ន**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម**

**ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- យោងតាមសេចក្ដីសំរេចរបស់រដ្ឋសភា ស្ដីពីការជ្រើសតាំងសម្ដេច **ជា ស៊ីម** ជាប្រធានរដ្ឋសភា ឯកឧត្តម **ឡូយ ស៊ីមឈាង** ជាអនុប្រធានទី ១ នៃរដ្ឋសភា នាសម័យប្រជុំពេញ អង្គលើកទី ១ នីតិកាលទី ១ ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ១៩៩៣
- យោងតាមសំណើរបស់ប្រធានរដ្ឋសភាស្ដីទី ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

**ត្រាស់បង្គាប់**

**មាត្រា ១ :** តែងតាំងឯកឧត្តម **នាង ណារិន** ជាទីប្រឹក្សាផ្ទាល់របស់ឯកឧត្តម **ឡូយ ស៊ីមឈាង** អនុប្រធានទី១នៃរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើអនុរដ្ឋលេខាធិការ ។

**មាត្រា ២ :** នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងអគ្គលេខាធិការរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ អោយបានសំរេច ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃពីឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៧

ក្នុងព្រះបរមនាម និង តាមព្រះរាជបញ្ជាប់បង្គាប់

**ប្រមុខរដ្ឋស្តីទី**

ហត្ថលេខា

**ជា ស៊ីម**

* * *

# II - រាជរដ្ឋាភិបាល

## ១_អនុក្រឹត្យ

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ១៩៩៧

**អនុក្រឹត្យលេខ : ១៦ អនក្រ.បក**

**ស្តីពីការបង្កើតអាជ្ញាធរជាតិ**

**សំរាប់តំបន់ពាណិជ្ជកម្មសេរីអាស៊ាន**

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួល សមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤.៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួល សមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៣២ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ១៩៩៦ ស្តីពីការចាត់តាំង និងការប្រព្រឹត្តិទៅ នៃប្រព័ន្ធសំរបសំរួលផ្ទៃក្នុង
- បានឃើញព្រះរាជក្រឹត្យលេខ រកត.០៧៩៦.២៩ ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ១៩៩៦ ស្តីពីការតែងតាំងលោក អូចព័ន្ធមុន្នីរ័ត ជាឧត្តមមន្ត្រីសេដ្ឋកិច្ច អមក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានឋានៈស្មើ អគ្គលេខាធិការ
- យោងតាមតម្រូវការចាំបាច់ នៃការងារ

**សំរេច**

**មាត្រា ១** : បង្កើតអង្គភាពជាតិសំរាប់តំបន់ពាណិជ្ជកម្មសេរី អាស៊ាន នៅក្រសួងសេដ្ឋកិច្ច ហិរញ្ញវត្ថុ ដែលជាភាសាអង់គ្លេសហៅថា «The National ASEAN Free Trade Area Unit »ហៅកាត់ថា «អង្គភាពជាតិ AFTA ឬ «National AFTA Unit »

**មាត្រា ២** :–អង្គភាពជាតិសំរាប់តំបន់ពាណិជ្ជកម្មសេរីអាស៊ានមានសមាសភាពដូចខាងក្រោម -

| | |
|---|---|
| ១–ឧត្តមមន្ត្រីសេដ្ឋកិច្ចអមក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | ប្រធាន |
| ២–ឧត្តមមន្ត្រីសេដ្ឋកិច្ចអម អមក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| ៣–តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៤–តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៥–តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៦–តំណាងក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល | សមាជិក |
| ៧–តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៨–តំណាងក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៩–តំណាងក្រសួងផែនការ | សមាជិក |
| ១០–នាយកទីចាត់ការគយ និងរដ្ឋាករនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |

១១–នាយក នៃនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

១២–នាយក នៃនាយកដ្ឋានអាស៊ាន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

**មាត្រា ៣ :** អង្គភាពជាតិសំរាប់តំបន់ពាណិជ្ជកម្មសេរីអាស៊ាន ប្រើប្រាស់នាយកដ្ឋានអាស៊ានរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុជាសេនាធិការ និងជាលេខាធិការដ្ឋានរបស់ខ្លួន ។

**មាត្រា ៤ :** អង្គភាពជាតិសំរាប់តំបន់ពាណិជ្ជកម្មសេរី អាស៊ានមានភារកិច្ចដូចតទៅ ÷

ក/–ជួយដល់មន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកម្ពុជា ក្នុងការរៀបចំគោលនយោបាយ និងកំណត់យុទ្ធសាស្ត្រកម្ពុជា ក្នុងការចូលជាសមាជិកនៃ តំបន់ពាណិជ្ជកម្មសេរីអាស៊ាន និងក្នុងការអនុវត្តន៍កិច្ចព្រមព្រៀង ស្តីពីការ អនុគ្រោះពន្ធគយរួមសំរាប់ AFTA(Agreement on Common Effective Preferential Tariff (CEPT) Scheme for the AFTA ) ។

ខ/–ទទួលបន្ទុកក្នុងការអនុវត្តន៍កិច្ចព្រមព្រៀង ស្តីពីការអនុគ្រោះពន្ធគយរួម ក្នុងនោះមាន ÷

– ការរៀបចំបញ្ជីទំនិញសំរាប់បញ្ចូលក្នុង CEPT Sheme ដែលក្នុងនោះរួមមាន ÷ បញ្ជីទំនិញសំរាប់បញ្ចូលក្នុង តារាងអនុគ្រោះពន្ធគយរួម ( Inclusion List ) បញ្ជីទំនិញដែលត្រូវដកចេញពីតារាងអនុគ្រោះពន្ធគយរួមជា បណ្តោះអាសន្ន ( Temporary Exclusion List ) បញ្ជីទំនិញដែលមានវេទយិតភាព និងបញ្ជីទំនិញដែលត្រូវ លើកលែងជាទូទៅ ( Sensitive and General Exception Lists ) ។

– ការរៀបចំកម្មវិធី និងកាលវិភាគ នៃការកាត់បន្ថយពន្ធគយសំរាប់ CEPT Scheme ។

– ការរៀបចំ «សៀវភៅផ្លាស់ប្តូរការអនុវត្តគ្រោះពន្ធគយសំរាប់ CEPT » ( CEPT Concessions Exchange Manual : CCEM )

– ការរៀបចំសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានមានា ដែលពាក់ព័ន្ធទៅនឹងការអនុវត្តន៍កិច្ចព្រមព្រៀង ស្តីពីការអនុគ្រោះពន្ធគយ ។

–កិច្ចការទំនាក់ទំនងសាធារណៈជាមួយផ្នែកឯកជនចំពោះការងារនានា ដែលមានការពាក់ព័ន្ធដល់ការអនុវត្តន៍កិច្ច ព្រមព្រៀង ស្តីពីការអនុគ្រោះពន្ធគយ ។

គ_តាមដាននិងវាយតម្លៃលើការអនុវត្តន៍កិច្ចព្រមព្រៀងស្តីពីការអនុវត្តន៍អនុគ្រោះពន្ធគយ ។

ឃ- ទទួលបន្ទុកជា « ចំណុចប្រមូលផ្តុំ » ( Focal Point ) នៅក្នុងទំនាក់ទំនងការងារ AFTA ជាមួយ លេខាធិការដ្ឋានអាស៊ាន និងជាមួយប្រទេសសមាជិកអាស៊ានដទៃទៀត ។

ង- សំរបសំរួល និងអនុវត្តកិច្ចសហប្រតិបត្តិការដទៃទៀតក្នុងក្របខ័ណ្ឌតំបន់ពាណិជ្ជកម្មសេរីអាស៊ាន ។

**មាត្រា ៥ :** សមាជិកនៃអង្គភាពជាតិសំរាប់តំបន់ពាណិជ្ជកម្មសេរីអាស៊ាន បំពេញការងារស្របតាមការអញ្ជើញរបស់ប្រធាន ។

**មាត្រា ៦ :** អង្គភាពជាតិសំរាប់តំបន់ពាណិជ្ជកម្មសេរីអាស៊ាន មានសិទ្ធិអញ្ជើញមន្ត្រីជំនាញ នៃក្រសួង និងស្ថាប័នពាក់ព័ន្ធនានាអោយចូលរួមប្រជុំ ដើម្បីពិភាក្សា និងដោះស្រាយការងារផ្សេង ៗ ដែលស្ថិតនៅក្នុងក្របខ័ណ្ឌតំបន់ពាណិជ្ជកម្មសេរីអាស៊ាន ។

**មាត្រា ៧ :** អង្គភាពជាតិសំរាប់ពាណិជ្ជកម្មសេរីអាស៊ានត្រូវរាយការណ៍ជាប្រចាំអំពីការងាររបស់ខ្លួន ដូចមានចែងក្នុងមាត្រា ៤ មកទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា៨ :** ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធនិងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃឡាព្រះហស្ថលេខា និង ចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ព្រះហស្ថលេខា និងត្រា ហត្ថលេខានិងត្រា

**នរោត្តម រណឫទ្ធិ ហ៊ុន សែន**

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មិនា ឆ្នាំ ១៩៩៧

**អនុក្រឹត្យលេខ : ១៨ អនក្រ.តត**

**ស្តីពីការតែងតាំងមន្ត្រីរាជការ**

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណូមពរក្រសួងការពារជាតិ

**សម្រេច**

**មាត្រា ១ :** តែងតាំងនាយទាហាន ដូចមានរាយនាមខាងក្រោមជាឧបការីសំរាប់ជួយការងារឯកឧត្តមឧត្តមសេនីយ៍ឯក **ឈឹម ឡឹមយ៉ុន** ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ ៖

-លោក វរសេនីយ៍ឯក **ជុំ សម៉ួន** ជាឧបការី បន្ថែមលើមុខងារបច្ចុប្បន្នជា
នាយករងនាយកដ្ឋានឃោសនា ខ.ភ.ម និងជា
អ្នកនាំពាក្យក្រសួងការពារជាតិ

-លោក វរសេនីយ៍ឯក **ខាយ គីមម៉េង** ជាឧបការី

-លោកវរសេនីយ៍ត្រី **គីម វិចិត្រ** ជាលេខាធិការផ្ទាល់

**មាត្រា ២ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងសន្តិសុខជាតិ នាយអគ្គសេនាធិការនៃកងយោធពលខេមរភូមិន្ទ

និងអស់លោកដែលមានឈ្មោះក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា តទៅ ។

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២
ព្រះហស្តលេខា និងត្រា ហត្ថលេខានិងត្រា
**នរោត្តម រណឫទ្ធិ** **ហ៊ុន សែន**

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ១៩៩៧

**អនុក្រឹត្យលេខ ១៩ អនក្រ.បក**

**ស្តីពីការជូនមេដាយស្ថាបនាជាតិ**

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រ កម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្ត[illegible]

**សម្រេច**

**មាត្រា ១** ៖ ផ្តល់មេដាយស្ថាបនាជាតិ[illegible]ជូនលោក GOTO FUMIO ជាជនជាតិ ជប៉ុន ដែលបានឧបត្ថម្ភថវិកាចំនួន ៣៣.៦៣៨ ដុល្លារអាមេរិក សម្រាប់សាងសង់

អាគារសិក្សាមួយខ្នង ព្រមទាំងសម្ភារៈ សិក្សាផ្តល់អោយសាលាបឋមសិក្សាផ្សារត្រាច ក្នុងឃុំលង្វែក ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ។

**មាត្រា ២ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពង់ឆ្នាំង ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផល ។

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២
ព្រះហស្តលេខា និងត្រា ហត្ថលេខានិងត្រា
**នរោត្តម រណឫទ្ធិ** **ហ៊ុន សែន**

* * *

## ២_សេចក្តីសំរេច

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ១៩៩៧

**សេចក្តីសំរេច លេខ : ១០ សសរ/គត**

**ស្តីពីការប្រគល់ការកិច្ចតាមដាន និងសំរបសំរួលកិច្ច សំរាប់ប្រតិបត្តិការសេដ្ឋកិច្ចតំបន់វិសាលភាពទន្លេមេគង្គ**

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងព្រះរាជក្រឹត្យលេខ ចស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួល សមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

- យោងតាមសំណូមពររបស់ភាគីពាក់ព័ន្ធការងារសហប្រតិបត្តិការសេដ្ឋកិច្ចតំបន់វិសាល ភាពទន្លេមេគង្គ
- តាមសំណើរបស់ក្រសួងផែនការ

## សម្រេច

**ប្រការ ១ :** ក្រសួងផែនការជាតំណាងរាជរដ្ឋាភិបាលក្នុងការទំនាក់ទំនង និង សំរបសំរួលជាមួយធនាគារអភិវឌ្ឍន៍អាស៊ី ( ADB ) ក្នុងក្របខ័ណ្ឌសហប្រតិបត្តិការ សេដ្ឋកិច្ចតំបន់វិសាលភាពទន្លេមេគង្គ ( Greater Mekong Sub Regional Cooperation ) ។

**ប្រការ ២ :** ក្រសួងផែនការមានភារកិច្ច ៖

- ទំនាក់ទំនង ឬ រៀបចំការប្រជុំអន្តរក្រសួងស្ថាប័នលើកពិភាក្សាខ្លឹមសារការងារក្នុងក្របខ័ណ្ឌ មេគង្គ ៦
- សំរបសំរួលការងារតាមគ្រប់គំរោងការរបស់ក្រសួងស្ថាប័ននីមួយ ៗ
- កសាងគំរោងបណ្តុះបណ្តាលសមត្ថភាពមន្ត្រីជំនាញ សំរាប់អនុវត្តគំរោងមេគង្គ ៦ អោយមានប្រសិទ្ធភាព
- ធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាលពីលទ្ធផលការងារជុំវិញបញ្ហាមេគង្គ ៦

**ប្រការ ៣ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធ ត្រូវទទួល អនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

| នាយករដ្ឋមន្ត្រីទី១ | នាយករដ្ឋមន្ត្រីទី២ |
|---|---|
| ព្រះហស្តលេខា និងត្រា | ហត្ថលេខានិងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

ភ្នំពេញ ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៧

**សេចក្តីសម្រេចលេខ: ១១ សសរ**

**ស្តីពីការជ្រើសតាំងជាបេក្ខជនទទួលរង្វាន់ SASAKAWA ៩៧**

* * *

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាព រាជរដ្ឋាភិបាល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតគណៈកម្មាធិការជាតិ គ្រប់គ្រងគ្រោះមហន្តរាយ
- បានឃើញសេចក្តីសម្រេចលេខ ៤៨ សសរ ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតលេខាធិការដ្ឋាន គ្រប់គ្រងគ្រោះមហន្តរាយ
- យោងតាមស្មារតីអង្គប្រជុំរបស់លេខាធិការដ្ឋាន នាថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៩៦

**សម្រេច**

**ប្រការ ១ :** ត្រូវបានជ្រើសតាំងឯកឧត្តម ញឹម វណ្ណដា រដ្ឋមន្ត្រីប្រតិភូ លេខាអចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិ គ្រប់គ្រងគ្រោះមហន្តរាយ ជាបេក្ខជនក្នុងការទទួលរង្វាន់ការពារគ្រោះមហន្តរាយ SASAKAWA ៩៧ ។

**ប្រការ ២ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងសាមីខ្លួន ដូចមានចែងក្នុងប្រការ ១ ត្រូវទទួលបន្ទុក អនុវត្តសេចក្តីសម្រេចនេះ ចាប់តាំងពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២
ព្រះហស្តលេខា និងត្រា ហត្ថលេខានិងត្រា
**នរោត្តម រណឫទ្ធិ ហ៊ុន សែន**

## II - ការងារបណ្ដាក្រសួង

### ១_ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

### ប្រកាស

ភ្នំពេញ,ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៧

**ប្រកាសលេខ: ០៥៣ សហវ.ប្រក.គរ**

**ស្ដីពីការយកកំរៃលើមុខទំនិញ នៃអគារលក់ទំនិញរួចពន្ធ**

* * *

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះ រាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីតែងតាំងរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសំរួលសមាសភាព រាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញតម្រូវការចាំបាច់របស់ក្រសួង

**សំរេច**

ប្រការ ១ : ទំនិញនាំចូលសំរាប់អគារលក់ទំនិញរួចពន្ធ (DUTY FREE SHOP) ត្រូវបង់កំរៃ ២% (ពីរភាគរយ) លើតំលៃ CIF ជូនអង្គការគយនិងរដ្ឋាករ ។ ការបង់កំរៃនេះអនុវត្តនៅតាមមាត់ច្រកនាំចូលទំនិញទាំងនោះតែម្ដង ។

**ប្រការ ២ :** សេចក្តីសំរេច និង ប្រកាសទាំងឡាយណាដែលផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៣ :** អគ្គនាយក នាយកខុទ្ទកាល័យ ប្រធានមន្ទីរ អង្គភាពពាក់ព័ន្ធ និងទីចាត់ការគយ និងរដ្ឋាករ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ពេត្យលោភ និងត្រា

**គាត ឈន់**

## ២_នីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## ប្រកាស

ភ្នំពេញ,ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៧

**ប្រកាសលេខ: ០៨១ ពណ.ឋក.ប្រក**

**ស្តីពីការបិទស្លាកថ្លៃលើមុខទំនិញ និងផ្នែកសេវាកម្មគ្រប់ប្រភេទ**

* * *

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម **សីហនុ** វរ្ម័ន ព្រះមហាក្សត្រនៃព្រះ រាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រមលេខ នស/រកម/១៩៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦

- បានឃើញច្បាប់ ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្មដែលប្រកាសអោយប្រើ ដោយព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី ២៦/០៦/១៩៩៥

**សម្រេច**

**ប្រការ ១ :** អាជីវករគ្រប់ប្រភេទដែលកំពុងធ្វើសកម្មភាពពាណិជ្ជកម្មក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបិទស្លាកថ្លៃតាមរាងតម្លៃលើគ្រប់មុខទំនិញឬលើផ្នែកសេវាកម្មរបស់ខ្លួនជាចាំបាច់។

**ប្រការ ២ :** រាល់ថ្លៃទាំងឡាយត្រូវកំណត់ជាប្រាក់រៀល ។

**ប្រការ ៣ :** ក្នុងករណីអាជីវករកំណត់ដាក់ថ្លៃជារូបិយវត្ថុបរទេសអាជីវករ ត្រូវមានការអនុញ្ញាតពីក្រសួងពាណិជ្ជកម្ម ។

**ប្រការ ៤ :** លិខិតអនុញ្ញាតអោយអាជីវករកំណត់ដាក់ថ្លៃជារូបិយវត្ថុបរទេស មានតំលៃក្នុងរយៈមួយឆ្នាំម្តង ។

**ប្រការ ៥ :** អាជីវករណាកំពុងធ្វើសកម្មភាពពាណិជ្ជកម្ម ពុំព្រមអនុវត្តតាមប្រកាសនេះនឹងត្រូវផ្តន្ទាទោស ពិន័យជាប្រាក់ពីប្រាំម៉ឺនរៀល (៥០.០០០រៀល) ទៅប្រាំសែនរៀល (៥០០.០០០ រៀល) ។

**ប្រការ ៦ :** ប្រធានមន្ទីរ ប្រធាននាយកដ្ឋានផែនការ ប្រធានមន្ទីរពាណិជ្ជកម្មគ្រប់ខេត្តក្រុងត្រូវអនុវត្តការកិច្ចរៀង ៗ ខ្លួនតាមប្រកាសនេះ ។

រដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
**ចម ប្រសិទ្ធ**

* * *

## ៣_ ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

## ប្រកាស

**ប្រកាសលេខ: ២២៥ ឧក. ប្រក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៧**

**ប្រការ ១ :** អនុញ្ញាតអោយអ្នកស្រី ម៉ាក់ ហោម ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ០៣៥១១៤ ភ.ព ចុះថ្ងៃទី ១១-០១-៨៥ អាស័យដ្ឋានបច្ចុប្បន្ន ផ្លូវលេខ

៦៨១ អឺ០ ផ្លូវព្រះមុនីវង្ស សង្កាត់បឹងកេងកងទី ៣ ខណ្ឌចំការមន រាជធានីភ្នំពេញ បន្តដំណើរការសិប្បកម្មផលិតឥដ្ឋ–ក្បឿង នៅក្នុងទីតាំង ភូមិត្នោតជ្រុំ សង្កាត់បឹងទំពុន ខណ្ឌមានជ័យរាជធានីភ្នំពេញ ។

**ប្រការ ២ :** ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

**ប្រកាសលេខ: ២២៦ ដក.ប្រក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៧**

**ប្រការ ១ :** អនុញ្ញាតអោយលោក ញ៉ាំង ហ៊ុក ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២៣១៥៩៦ ចុះថ្ងៃទី ២៥–៦–៩២ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ១៤៩ អឺ២ ផ្លូវលេខ ១៦៥ សង្កាត់អូរឫស្សីទី២ ខណ្ឌ៧មករា រាជធានីភ្នំពេញ បន្តដំណើរការរោងជាងក្រឡឹងដែក នៅក្នុងទីតាំងផ្ទះលេខ ៦៤អឺ០ ផ្លូវលេខ ១៤៩ សង្កាត់ផ្សារកណ្តាលទី២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

**ប្រការ ២ :** ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

**ប្រកាសលេខ: ២២៧ ដក.ប្រក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៧**

**ប្រការ ១ :** អនុញ្ញាតអោយលោក អារ់ ហាប់ ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២២១៧៤៨ ភ.ព ចុះថ្ងៃទី ០៨–៤–៨៩ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៨៣ ផ្លូវលេខ ១៤៨ សង្កាត់ផ្សារកណ្តាលទី២ ខណ្ឌ ដូនពេញ រាជធានីភ្នំពេញ បន្តដំណើរការរោងជាងក្រឡឹងដែក នៅក្នុងទីតាំងផ្ទះលេខ៨៣ អឺ០ សង្កាត់ផ្សារកណ្តាលទី២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

**ប្រការ ២ :** ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណងឡើយ ។

* * *

**ប្រកាសលេខ: ២២៨ ឧក.ប្រក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៧**

**ប្រការ ១ :** អនុញ្ញាតអោយលោក គាត ញាយ ជាម្ចាស់មូលដ្ឋានផលិតសំបកកង់សញ្ញា «ផែនដី» ដែលមាន ទីតាំង ផ្ទះសង់ថ្មី ភូមិទួលសង្កែ សង្កាត់ទួលសង្កែ ខ័ណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ផ្ទេរសិទ្ធិគ្រប់គ្រងជូនលោក ហុង គៀត វិញ ។

**ប្រការ ២ :** ទទួលស្គាល់លោក ហុង គៀត ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ៣២៦២៩៦ ភ.ព ចុះថ្ងៃទី ០១-០១-៩២ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះសង់ថ្មី ផ្លូវទួលសង្កែ ភូមិទួលសង្កែ សង្កាត់ទួលសង្កែ ខ័ណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ជាម្ចាស់សហគ្រាសកម្មន្តផលិតសំបកកង់ សញ្ញា « ផែនដី » ដែលមានទីតាំង ដូចមានចែងក្នុងប្រការ ១ ។

**ប្រការ ៣ :** ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណងឡើយ ។

* * *

**ប្រកាសលេខ: ២២៩ ឧក.ប្រក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៧**

**ប្រការ ១ :** អនុញ្ញាតអោយលោក សៀក គួង ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៧៦១៧៨ ភ.ព ចុះថ្ងៃទី ០២-៣-៩៣ អាស័យដ្ឋានបច្ចុប្បន្ន ផ្លូវលេខ ២៧អឺ០ ផ្លូវលេខ ១៧៨ សង្កាត់បឹងរាំង ខ័ណ្ឌ ដូនពេញ រាជធានីភ្នំពេញ បន្តដំណើរការសិប្បកម្មផលិតឥដ្ឋការ៉ូ នៅក្នុងទីតាំងផ្ទះលេខ ២៧ អឺ០ ផ្លូវលេខ ១៧៨ សង្កាត់បឹងរាំង ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ ។

**ប្រការ ២ :** ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការ អនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

**ប្រកាសលេខ: ២៣០ ឧក.ប្រក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៧**

**ប្រការ ១ :** អនុញ្ញាតអោយលោក សាន់ សៀងហួត ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២០៨៧៩២ ភ.ព ចុះថ្ងៃទី ០៥–១២–៨៤ អាសយដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ១០៤ ផ្លូវលេខ ១៩៦ សង្កាត់ទឹកល្អក់ ខណ្ឌទួលគោក រាជធានីភ្នំពេញ បន្តដំណើរការសិប្បកម្មផលិតនំប៉័ងឈ្មោះ «កែវតាទី» នៅក្នុងទីតាំងផ្ទះលេខ ១៣៧ ផ្លូវលេខ ១៩៦ ក្រុមទី ៤ សង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

**ប្រការ ២ :** ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការ អនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

**ប្រកាសលេខ: ២៣១ ឧក.ប្រក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៧**

**ប្រការ ១ :** អនុញ្ញាតអោយលោក យូ ហៀង ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២១៤២៣១ ភ.ព ចុះថ្ងៃទី ០៦–៤–៨៩ អាសយដ្ឋានបច្ចុប្បន្ន ផ្ទះសង់ថ្មី ផ្លូវលេខ ៣៣៦ ក្រុមទី ២០ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ បន្តដំណើរការសិប្បកម្មផលិតនំផ្អែមឈ្មោះ «ប៉េងហ៊ោង» សញ្ញា «ទន្សាយពីរ» នៅក្នុងទីតាំងដូចអាសយដ្ឋានខាងលើ ។

**ប្រការ ២ :** ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្ត

ល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

**ប្រកាសលេខ: ២៣២ ឧក.ប្រក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៧**

**ប្រការ ១ :** អនុញ្ញាតអោយលោក ហ៊ូ សំអុល ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ៣៤៤៧៥៩ ភ.ព ចុះថ្ងៃទី ០២–០១–៩៣ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ២០០ AEO ផ្លូវលេខ ១៨២ សង្កាត់ផ្សារដេប៉ូទី១ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ បន្តដំណើរការសិប្បកម្មកិនម្សៅអង្ករ នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ

**ប្រការ ២ :** ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ផលិតផលគ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយ គ្មានសំណងឡើយ ។

* * *

**ប្រកាសលេខ: ២៣៣ ឧក.ប្រក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៧**

**ប្រការ ១ :** អនុញ្ញាតអោយលោក ហុង ម៉ៅ ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៨២៣៧៤ ភ.ព ចុះថ្ងៃទី ២៣–៣–៩៥ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៧៥ ក ផ្លូវលេខ ២៧៨ សង្កាត់អូរឡាំពិក ខ័ណ្ឌចំការមន រាជធានីភ្នំពេញ បន្តដំណើរការឧស្សាហកម្មតូចផលិតកៅស៊ូកងយីហោ «ហុងម៉ៅ»សញ្ញា «រូបដី» នៅក្នុងទីតាំងផ្ទះលេខ ៧៥ ក ផ្លូវលេខ ២៧៨ សង្កាត់អូរឡាំពិក ខ័ណ្ឌចំការមន រាជធានីភ្នំពេញ ។

**ប្រការ ២ :** ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការ អនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

**ប្រកាសលេខ: ២៣៤ ផក.ប្រក ចុះថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៧**

**ប្រការ ១ :** អនុញ្ញាតអោយលោក គី ឈាងហួត ជាម្ចាស់សិប្បកម្មផលិតឥដ្ឋ–ក្បឿង ដែលមានទីតាំងភូមិស្វាយ ជ្រុំ ឃុំព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្តាល ផ្ទេរភារកិច្ចគ្រប់គ្រងជូនលោកខឹម សម្បត្តិ វិញ ។

**ប្រការ ២ :** ទទួលស្គាល់លោក ខឹម សម្បត្តិ ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ៣៦៦២៨៧ ភ.ព. ចុះថ្ងៃទី ១១–១២–៩២ អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ ២៧៣ ផ្លូវលេខ ១៥៨ សង្កាត់ផ្សារកណ្តាលទី១ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ជាម្ចាស់សិប្បកម្មផលិតឥដ្ឋ–ក្បឿង ដែលមានទីតាំង ដូចមានចែងក្នុងប្រការ ១ ។

**ប្រការ ៣ :** ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

**អ៊ិត ប្រាំង**

* * *

## ៤_ទីស្តីការរដ្ឋមន្ត្រីក្រសួងពត៌មាន

## ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៧

**ប្រកាសលេខ ០៨១ ពម.ប្រក**

**អនុញ្ញាតអោយកាសែត «ជាតិ» បន្តការចេញផ្សាយឡើងវិញ**

* * *

**ប្រការ ១ :** អនុញ្ញាតអោយកាសែត «ជាតិ» បន្តការចេញផ្សាយឡើងវិញដោយមានលោក ម៉ា ណារិទ ជាចាងហ្វាងការផ្សាយទីស្នាក់ការលេខ ៦៩ ផ្លូវសុធារស សង្កាត់ទន្លេ

បាសាក់ ខ័ណ្ឌចំការមនភ្នំពេញ ។ ក្នុងករណីមានការផ្លាស់ប្តូរចំណុចណាមួយក្នុង អត្តសញ្ញាណ នៃកាសែតរបស់ ត្រូវជូនដំណឹង ជាមុន ៥ ថ្ងៃ មកក្រសួងពត៌មាន ដើម្បីរៀបចំសេចក្តីសំរេចជាថ្មី ។

**ប្រការ ២ :** ប្រកាសលេខ ១៣៨៩/៩៤ ពម ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ១៩៩៤ ស្តីពីការអនុញ្ញាតអោយកាសែត « ជាតិ » ចេញផ្សាយត្រូវទុកជានិរាករណ៍ ។

**ប្រការ ៣ :** រាល់ដំណើរការបោះពុម្ពចែកផ្សាយត្រូវគោរពតាមគោលការណ៍ ក្រមសីលធម៌អ្នកកាសែត ច្បាប់ស្តីពីរបបសារពត៌មាន និងច្បាប់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា រួចត្រូវប្រគល់កាសែតចំនួន០៦ ច្បាប់ រៀងរាល់លេខចេញផ្សាយមកដំកល់ទុកជាឯកសារនៅក្រសួងពត៌មាន ។

**ប្រការ ៤ :** ក្នុងករណីប្រព្រឹត្តិល្មើស និងសេចក្តីដូចមានចែងក្នុងប្រការទាំងឡាយខាងលើនេះ សាម៉ីខ្លួនត្រូវទទួល ទោសតាមច្បាប់ជាធរមាន ។

**ប្រការ ៥ :** អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានមណ្ឌលពត៌មាន នៃក្រសួងពត៌មាន និង ចាងហ្វាងកាសែត «ជាតិ» ត្រូវអនុវត្តន៍នូវប្រកាសនេះ ។

**ប្រការ ៦ :** ប្រកាសនេះមានប្រសិទ្ធភាពរយៈពេល ២ ឆ្នាំ និងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និត្រា

**ខៀវ កាញារីទ្ធ**

* * *

ភ្នំពេញ ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៧

**ប្រកាស លេខ: ០៨២.៩៧ ឯក.ប្រក**

រដ្ឋមន្ត្រីក្រសួងពត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ជំពូក ៣ មាត្រាទី ៤១
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល

- បានឃើញច្បាប់ស្តីពីរបបសារពត៌មាននៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើ តាមព្រះរាជក្រម លេខ នស/រកម/០៨៩៥/០៧ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥

**សំរេច**

**ប្រការ ១** : យោងមាត្រាទី ៨ ជំពូក ២ លោក ព្រាំ គិម ជាម្ចាស់ការផ្សាយទស្សនាវដ្តី FOCUS CAMBODIA បានរំលោភដោយចេញផ្សាយក្នុងឆ្នាំ១៩៩៦ ដោយមិនជូនដំណឹងដល់ក្រសួងពត៌មានជាមុន ក្រសួងសូមធ្វើការដាក់ពិន័យក្រិតស្រាលចំនួន ៥០០.០០០ រៀល ( ប្រាំសែនរៀល) ទុកជាការព្រមាន ។

**ប្រការ ២** : ទឹកប្រាក់ដែលបានពីការដាក់ពិន័យក្នុងប្រការ ១ ត្រូវបង់ចូលថវិការដ្ឋ ។

**ប្រការ ៣** : អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នាយកដ្ឋានមណ្ឌលពត៌មាន នាយកដ្ឋានគណនេយ្យ នៃក្រសួងពត៌មាន និងលោក ព្រាំ គិម ត្រូវអនុវត្តនូវប្រកាសនេះ ។

**ប្រការ ៤** : ប្រកាសនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

**ខៀវ កាញារីទ្ធ**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៧

**ប្រកាស លេខ : ០៨៣.៩៧ ពម.ប្រក**

រដ្ឋមន្ត្រីក្រសួងពត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល ចុះថ្ងៃទី ០១-១១-១៩៩៣
- បានឃើញព្រះរាជក្រម ចុះថ្ងៃទី ២៤-០១-១៩៩៦ ស្តីពីការបង្កើតក្រសួងពត៌មាន
- យោងលិខិតស្នើសុំអនុញ្ញាតច្បាប់ បើកអាជីវកម្មរោងពុម្ព របស់អ្នកស្រី ខៀវ មាលី ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

សម្រេច

**ប្រការ ១** : អនុញ្ញាតជូនអ្នកស្រី ខៀវ មាលី ស្ថិតនៅផ្ទះលេខ ៣ ផ្លូវលេខ ៣៣៤ ក្រុមទី ៦៣ សង្កាត់បឹងកេងកង១ ខណ្ឌចំការមនរាជធានីភ្នំពេញ បើកអាជីវកម្មរោងពុម្ពដែរមានឈ្មោះ BLOSSOM LOTUS PUBLISHING COMPANY ទីតាំងស្ថិតនៅក្នុងអាស័យដ្ឋានខាងលើ ។

**ប្រការ ២** : រាល់ដំណើរការបោះពុម្ពផ្សាយ ត្រូវអនុវត្តតាមកិច្ចសន្យា សមស្របតាមទំនៀមទំលាប់សន្តិសុខ សណ្តាប់ធ្នាប់សង្គម និង ច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ៣** : ករណីប្រព្រឹត្តិល្មើសដូចមានចែងក្នុងប្រការ ២ សាមីខ្លួនត្រូវទទួលខុសត្រូវតាមច្បាប់ជាធរមាន ។

**ប្រការ ៤** : នាយកដ្ឋានគ្រប់គ្រងការបោះពុម្ពផ្សាយ និង សោតទស្សន៍ នៃក្រសួងពត៌មាន និងប្រធានមន្ទីរពត៌មាន រាជធានីភ្នំពេញ ត្រូវទទួលអនុវត្តតាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ៥** : ប្រកាសនេះ មានអានុភាពអនុវត្តិ ចាប់ពីថ្ងៃចុះ ហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

**ខៀវ កាញារីទ្ធ**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ៩៩៨

**ប្រកាសលេខ ០៨៤/៩៧ ពម.ប្រក**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រម ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងពត៌មាន
- យោងលិខិតស្នើសុំអនុញ្ញាតច្បាប់បើកអាជីវកម្មរោងពុម្ព «អមរា» របស់អ្នកស្រី រស់ អួន ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

**សំរេច**

**ប្រការ ១ :** អនុញ្ញាតជូនអ្នកស្រី រស់ អ៊ួន ស្ថិតនៅផ្ទះលេខ៣៧E០ ផ្លូវលេខ ១១៨ សង្កាត់ផ្សារកណ្តាល ១ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញបើកអាជីវកម្មរោងពុម្ព «អមរា» ដែលមានទីតាំងស្ថិតនៅលំនៅស្ថានខាងលើ ។

**ប្រការ ២ :** រាល់ដំណើរការបោះពុម្ពផ្សាយ ត្រូវអនុវត្តតាមកិច្ចសន្យា សមស្របតាមទំនៀមទំលាប់ សន្តិសុខសណ្តាប់ធ្នាប់សង្គម និងច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ៣ :** ក្នុងករណីប្រព្រឹត្តល្មើស ដូចមានចែងក្នុងប្រការ ២ សាមីខ្លួនត្រូវទទួលខុសត្រូវតាមច្បាប់ជាធរមាន ។

**ប្រការ ៤ :** ប្រធាននាយកដ្ឋានគ្រប់គ្រងការបោះពុម្ពផ្សាយ និងសោតទស្សន៍ និងប្រធានមន្ទីរពត៌មានរាជធានីភ្នំពេញ ត្រូវទទួលអនុវត្តតាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ៥ :** ប្រកាសនេះមានអនុភាព គតិយុត្តិចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

**ខៀវ កាញារីទ្ធ**

* * *

ភ្នំពេញ,ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ១៩៩៧

**ប្រកាស លេខ: ០៨៦–៩៧ ពម.ប្រក**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ជំពូក ៣ មាត្រាទី ៤១
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ស្តីពីរបបសារពត៌មាន នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ លេខ នស/.ក.ម ០៨៩៥.០៧ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥
- បានឃើញប្រកាសរបស់ក្រសួងពត៌មានលេខ ២៦៨/៩៥ ពម.ប្រក ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៥ ។

- បានឃើញកំណត់ហេតុ នៃអង្គប្រជុំស្ដីពីការរៀបចំរចនាសម្ព័ន្ធ និងលក្ខន្តិកៈថ្មីរបស់ពត៌មានអ្នកប្រយុទ្ធ ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៧
- បានឃើញលិខិតរបស់អង្គប្រជុំតែងតាំងលោក អ៊ុន សុខុម ជាចាងហ្វាងការផ្សាយ ចុះថ្ងៃទី ៣ ខែ មីនា ឆ្នាំ ១៩៩៧

**សម្រេច**

**ប្រការ ១ :** ទទួលស្គាល់លោក អ៊ុន សុខុម ជាចាងហ្វាងការផ្សាយកាសែត «អ្នកប្រយុទ្ធ » ដែលមានទីស្នាក់ការ លេខ២៧ ផ្លូវ២៤០ សង្កាត់អូឡាំពិកខណ្ឌចំការមន ក្រុងភ្នំពេញ ។ ក្នុងករណីមានការផ្លាស់ប្ដូរចំណុចណាមួយក្នុងអត្តសញ្ញាណ នៃកាសែតរបស់ខ្លួនត្រូវជូនដំណឹងជាមុន ៥ ថ្ងៃ មកក្រសួងពត៌មានដើម្បីរង់ចាំសេចក្ដីសំរេចជាថ្មី ។

**ប្រការ ២ :** រាល់ដំណើរការបោះពុម្ពចែកផ្សាយ ត្រូវគោរពតាមគោលការណ៍ ក្រមសីលធម៌អ្នកកាសែត ច្បាប់ស្ដីពីរបបសារពត៌មាន នឹងច្បាប់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជារួចត្រូវប្រគល់កាសែតចំនួន ០៦ ច្បាប់ រៀងរាល់លេខចេញផ្សាយមកដំកល់ទុកជាឯកសារនៅក្រសួងពត៌មាន ។

**ប្រការ ៣ :** ក្នុងករណីប្រព្រឹត្តិល្មើស នឹងសេចក្ដីដូចមានចែងក្នុងប្រការទាំងឡាយខាងលើនេះសាម៉ីខ្លួនត្រូវទទួល ទោសតាមច្បាប់ជាធរមាន ។

**ប្រការ ៤ :** អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានមណ្ឌលពត៌មាន នៃក្រសួងពត៌មាន និង ចាងហ្វាងកាសែត «អ្នកប្រយុទ្ធ » ត្រូវអនុវត្តន៍នូវប្រកាសនេះ ។

**ប្រការ ៥ :** ប្រកាសនេះមានប្រសិទ្ធភាពរយៈពេល ៣ ឆ្នាំ ហើយសេចក្ដី សំរេចណាដែលផ្ទុយនឹងសេចក្ដីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ និង ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

**ខៀវ កាញារីទ្ធ**

* * *

ភ្នំពេញ ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ១៩៩៧

**ប្រកាសលេខ: ០៨៧–៩៧ ពម.ប្រក**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ជំពូក ៣ មាត្រាទី ៤១ ។
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម** **សីហនុ** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ស្តីពីរបបសារពត៌មាន នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ លេខ នស.រ.ក.ម ០៨៩៥.០៧ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥
- បានឃើញប្រកាសរបស់ក្រសួងពត៌មានលេខ ៥៩៩/៩៤ ពម. ចុះថ្ងៃទី ២ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការអនុញ្ញាតអោយកាសែត « ភ្នំពេញថ្មី » បោះពុម្ពចែកផ្សាយ ដោយមានលោក ឃុន ង៉ោ ជាចាងហ្វាងការផ្សាយ និងលិខិតផ្ទេរសិទ្ធិចាងហ្វាងចុះថ្ងៃទី ៨ កក្កដា ឆ្នាំ ១៩៩៤ ពីលោក ឃុនង៉ោ ជូនទៅលោក ថៃ នរៈសត្យាវិញ
- បានឃើញសំណើសុំច្បាប់ចេញផ្សាយបន្តកាសែត « ភ្នំពេញថ្មី » ឡើងវិញរបស់លោក ថៃ នរៈសត្យា ចុះថ្ងៃទី ១៦/១២/៩៦

**សំរេច**

**ប្រការ ១ :** អនុញ្ញាតអោយចេញផ្សាយបន្តឡើងវិញកាសែត «ភ្នំពេញថ្មី» ដោយមានលោក ថៃ នរៈសត្យា ជាចាងហ្វាងការផ្សាយ ។ ទីស្នាក់ការលេខ ១២៥អឹ០ ផ្លូវ ១៣៤ សង្កាត់ផ្សារដេប៉ូ២ ខ័ណ្ឌទួលគោកក្រុងភ្នំពេញ ។ ក្នុងករណីមានការផ្លាស់ប្តូរចំណុចណាមួយក្នុងអត្តសញ្ញាណ នៃកាសែតរបស់ខ្លួនត្រូវជូនដំណឹងជាមុន៥ ថ្ងៃ មកក្រសួងពត៌មានដើម្បី រង់ចាំសេចក្តីសំរេចជាថ្មី ។

**ប្រការ ២ :** ប្រកាសលេខ ៥៩៩/៩៤ ពម ចុះថ្ងៃទី ០២ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពីការ អនុញ្ញាតអោយកាសែត « ភ្នំពេញថ្មី » ចេញផ្សាយនិងប្រកាសបិទរបស់ក្រសួង ពត៌មានលេខ ១៥១/៩៤ ពម.ប្រក ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ១៩៩៤ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៣ :** រាល់ដំណើរការបោះពុម្ពចែកផ្សាយត្រូវគោរពតាមគោលការណ៍ ក្រមសីលធម៌ អ្នកកាសែតច្បាប់ ស្តីពីរបបសារពត៌មាន និងច្បាប់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

រួចត្រូវប្រគល់កាសែតចំនួន ០៦ ច្បាប់ រៀងរាល់លេខផ្សាយមកដាក់ទុកជាឯកសារ នៅក្រសួងពត៌មាន ។

**ប្រការ ៤ :** ក្នុងករណីប្រព្រឹត្តិល្មើស និងសេចក្តីដូចមានចែងក្នុងប្រការទាំងឡាយខាងលើនេះ សាមីខ្លួនត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

**ប្រការ ៥ :** អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានមណ្ឌលពត៌មាន នៃក្រសួងពត៌មាន និង ចាងហ្វាងកាសែត « ភ្នំពេញថ្មី » ត្រូវអនុវត្តន៍នូវប្រកាសនេះ ។

**ប្រការ ៦ :** ប្រកាសនេះមានប្រសិទ្ធភាពរយៈពេល ២ ឆ្នាំ និងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

**ខៀវ កាញារីទ្ធ**

* * *

## ៥_ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## ប្រកាស

ភ្នំពេញ,ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ១៩៩៧

**ប្រកាសលេខ: ១៨២ អយ.ប្រក**

**ស្តីពីការអនុញ្ញាតអោយបោះពុម្ពសៀវភៅគណិតវិទ្យា**

**« សំរាប់សិស្សថ្នាក់ទី ៨ »**

* * *

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ លេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ កែសម្រួល សមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ។
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤/មករា/៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានពិនិត្យលិខិតស្នើសុំនាមលេខ ៣១៨ អយក.ស្នទន ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៥ របស់ក្រសួងអប់រំយុវជន និងកីឡា ស្តីពីការបង្កើតគណៈកម្មការកែលំប្រព័ន្ធអប់រំ
- បានពិនិត្យរបាយការណ៍របស់គណៈកម្មការ ពិនិត្យខ្លឹមសារសៀវភៅគណិតវិទ្យាថ្នាក់ទី ៨ ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

**សំរេច**

**ប្រការ ១ :** អនុញ្ញាតអោយបោះពុម្ពផ្សាយសៀវភៅគណិតវិទ្យាសំរាប់សិស្សថ្នាក់ទី ៨ ដែលជាស្នាដៃនិពន្ធរបស់គណៈកម្មការគណិតវិទ្យាមធ្យមសិក្សា នៃវិទ្យាស្ថានស្រាវជ្រាវក្រសួងអប់រំយុវជន និងកីឡា និងរៀបរៀងដោយ លោក អ៊ុន គឹមស្រ៊ុន ដើម្បីប្រើប្រាស់នៅតាមសាលារៀនចំនេះទូទៅ ។

**ប្រការ ២ :** មន្ទីរ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការហិរញ្ញកិច្ច វិទ្យាស្ថានស្រាវជ្រាវគ្រឹះស្ថាន បោះពុម្ពផ្សាយអប់រំ មជ្ឈមណ្ឌលចែកផ្សាយ បណ្ណាល័យ នាយកដ្ឋានចំនេះទូទៅ និងមន្ត្រីយសិក្សា មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់តាំងពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**តុល ឡោះ**

* * *

ភ្នំពេញ,ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ១៩៩៧

**ប្រកាស លេខ: ១៨៣ អយក.ប្រក**

**ស្តីពីការអនុញ្ញាតអោយបោះពុម្ពសៀវភៅគីមីវិទ្យា**

**« សំរាប់គ្រូថ្នាក់ទី ៨ »**

រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
– បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
– បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ កែសំរួល សមាសភាពរាជរដ្ឋាភិបាល
– បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
– បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤/មករា/៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
– បានពិនិត្យលិខិតឧទ្ទេសនាមលេខ ៣១៨ អយក.ឧទន ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៥ របស់ក្រសួងអប់រំយុវជន និងកីឡា ស្តីពីការបង្កើតគណៈកម្មការកែលំ ប្រព័ន្ធអប់រំ
– បានពិនិត្យរបាយការណ៍របស់គណៈកម្មការ ពិនិត្យខ្លឹមសារសៀវភៅគីមីវិទ្យាថ្នាក់ទី ៨ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

**សំរេច**

**ប្រការ ១ :** អនុញ្ញាតអោយបោះពុម្ពផ្សាយសៀវភៅគីមីវិទ្យាសំរាប់គ្រូថ្នាក់ទី ៨ ដែលជាស្នាដៃនិពន្ធ របស់គណៈកម្មការគីមីវិទ្យាមធ្យមសិក្សា នៃវិទ្យាស្ថានស្រាវជ្រាវក្រសួងអប់រំយុវជន និងកីឡា និងរៀបរៀងដោយ លោក ស៊ុន ប៊ុណ្ណា ដើម្បីប្រើប្រាស់នៅតាមសាលារៀនចំនេះទូទៅ ។

**ប្រការ ២ :** មន្ទីរ នាយកដ្ឋានចាត់តាំង នាយកដ្ឋានផែនការហិរញ្ញកិច្ច វិទ្យាស្ថានស្រាវជ្រាវគ្រឹះស្ថាន បោះពុម្ពផ្សាយអប់រំ មជ្ឈមណ្ឌលចែកផ្សាយ បណ្ណាល័យ នាយកដ្ឋាន

ចំនេះទូទៅ និងមត្តេយ្យសិក្សា មានភារកិច្ចអនុវត្តសេចក្ដីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់តាំងពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**តូល ឡោះ**

* * *

ភ្នំពេញ ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ១៩៩៧

**ប្រកាសលេខ: ១៨៤ អយក. ប្រក**

**ស្ដីពីការប្ដូរឈ្មោះសាលាបថមសិក្សា ទួលក្រសាំង**

**មកជាសាលាបថមសិក្សា អ៊ីវហា ទួលក្រសាំង**

* * *

រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាលេខ នស/រកត/០៧៩៦-៥២ ចុះថ្ងៃទី ២៦ ខែ ៧ ឆ្នាំ ១៩៩៦ ស្ដីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ ឆ្នាំ
- បានឃើញលិខិតស្នើសុំរបស់នាយកសាលាបថមសិក្សាឃុំរកាខ្ពស់ចុះថ្ងៃទី ២៩-០១-៩៧
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំនេះទូទៅ និង មត្តេយ្យសិក្សា

**សំរេច**

**ប្រការ ១** : អនុញ្ញាតអោយមន្ទីរអប់រំយុវជន និងកីឡាខេត្តកណ្តាល ប្តូរឈ្មោះសាលាបឋមសិក្សា" ទួលក្រសាំង " ដែលមានទីតាំងស្ថិតនៅឃុំរកាខ្ពស់ ស្រុកស្អាង ខេត្តកណ្តាល មកជាសាលាបឋមសិក្សា " អ៊ីរ៉ូហោទួលក្រសាំង " វិញចាប់ពីឆ្នាំសិក្សា ១៩៩៦–៩៧ នេះតទៅ ។

**ប្រការ ២** : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ២** : ប្រធានមន្ទីរ ក្រសួងអប់រំយុវជន និង កីឡា ប្រធាននាយកដ្ឋានចាត់តាំង នាយកដ្ឋានផែនការហិរញ្ញកិច្ច ប្រធាននាយកដ្ឋានបំនេះទូទៅ និងមត្តេយ្យសិក្សា ប្រធានមន្ទីរអប់រំយុវជន និងកីឡាខេត្តកណ្តាល ការិយាល័យអប់រំ យុវជន និង កីឡា ស្រុកស្អាង នាយកសាលាបឋមសិក្សា " អ៊ីរ៉ូហោទួលក្រសាំង " មានភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**តុល ឡោះ**

* * *

## ៦_នីតិការក្រសួងធម្មការ និង សាសនា

### សេចក្តីសំរេច

ភ្នំពេញ,ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៧

**សេចក្តីសំរេច លេខ: ៤៣.៩៧ កធស**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា ដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ នសរកម ០១៩៦–១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦

- បានឃើញច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជាលេខ ០៦ នស ១៩៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០/៦/៩២ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅ នៃក្រសួងធម្មការ និង សាសនា
- បានឃើញពាក្យសុំបើកសាខាស្នាក់ការថ្វាយបង្គំព្រះ នៃសាសនា មីលិក (ចិន ) របស់ លោកស្រី ខូវ អិច ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៦
- មានចំណារបញ្ជូនរបស់ឯកឧត្តម អភិបាលខេត្តកំពត លេខ ៤០០ លចបកព-៩៦ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦

## សម្រេច

**ប្រការ ១** : អនុញ្ញាតជាគោលការណ៍អោយ បើកសាខាស្នាក់ការថ្វាយបង្គំព្រះ នៃសាសនា មីលិក (ចិន) មួយកន្លែងដែលមានទីតាំងស្ថិតនៅ ភូមិកំពង់ត្រាចទី ១ ឃុំកំពង់ត្រាចខាងលើស្រុកកំពង់ត្រាច ខេត្តកំពត ។

**ប្រការ ២** : សាខាស្នាក់ការថ្វាយបង្គំព្រះ នៃសាសនាមីលីក (ចិន) ត្រូវអនុញ្ញាតអោយប្រើប្រាស់ និងផ្សព្វផ្សាយនូវរាល់ឯកសារផ្សេង ។ របស់លទ្ធិសាសនា (ចិន) ដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

**ប្រការ ៣** : បរិស័ទទាំងអស់របស់សាសនាមីលីក (ចិន) នេះត្រូវគោរព និងអនុវត្តន៍អោយបានត្រឹមត្រូវម៉ឺងម៉ាត់តាមច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា និងរាល់បទបញ្ញត្តិផ្សេងៗ របស់ក្រសួងធម្មការ និង សាសនា ។ អ្នកដឹកនាំ សាខាស្នាក់ការខាងលើនេះ ត្រូវមានសាមគ្គីភាព និង ទំនាក់ទំនងអោយបានល្អ ជាមួយស្ថាប័នពាក់ព័ន្ធ សន្យាជាដាច់ខាតមិនធ្វើអោយប៉ះពាល់ដល់សិទ្ធិសេរីភាពខាងជំនឿសាសនា និង សណ្តាប់ធ្នាប់របៀបរៀបរយសង្គម ។

**ប្រការ ៤** : រាល់ការណ៍អនុវត្តន៍ទាំងឡាយណា ដែលផ្ទុយអំពីសេចក្តីសម្រេចខាងលើនេះ ត្រូវទទួលទោសតាម ច្បាប់ជាធរមាន ។

**ប្រការ ៥ :** នាយកដ្ឋានសាសនា–មន្ទីរធម្មការ និងសាសនាខេត្តកំពត និងមន្ត្រីរាជការគ្រប់គ្រងលំដាប់ថ្នាក់ដែលមានភារកិច្ចពាក់ព័ន្ធ ត្រូវសហការអនុវត្តន៍សេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពខ្ពស់ ។

**ប្រការ ៦ :** សេចក្តីសំរេចនេះមានអនុភាពអនុវត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

**ហឿន វណ្ណារ័ត្ន**

* * *

បោះពុម្ពនៅរោងពុម្ព ទីស្តីការគណៈរដ្ឋមន្ត្រី
លើកទី១ ចំនួន ៨០០ ច្បាប់

តម្លៃ ២៧៥០ រៀល